១០–លោក **សុក ស៊ីអាន** មន្ត្រីការិយាល័យគណនេយ្យហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១១–លោក **ឃួត ធុន្នី** តំណាងក្រសួងយុត្តិធម៌ សមាជិក

១២–លោក **កាំង លាងខំណុ** អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការនិងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការឯកជនភាវូបនីយកម្ម

១៣–លោក **ជុំ ទិជិត្ត** មន្ត្រីខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកលេខាធិការដ្ឋាន

១៤–លោក **ឡាំ សុផល** មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិកលេខាធិការដ្ឋាន

១៥–លោក **នួន សំបូរ** មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសមាជិកលេខាធិការដ្ឋាន

**ប្រការ ២** : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធព្រមទាំងសាមីខ្លួន ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា និង ត្រា**

**គាត ឈន់**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០០៤ សហវ.មប្រក**

**ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

**សំរេច**

**ប្រការ ១ :** បទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ ដែលមានចែងក្នុងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ត្រូវចាប់ផ្តើមអនុវត្តចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៦ ចំពោះក្រសួងនានា ដែលជាអាណាប័កដើមខ្សែទាំងអស់ និងរតនាគារជាតិព្រមទាំង គណនេយ្យសាធារណៈ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ដើម្បីអនុវត្តកិច្ចប្រតិបត្តិការ ចំណូល ចំណាយ ថវិការដ្ឋ ។ ការអនុវត្តដោយអាណាប័កតាមការប្រទានសិទ្ធិ និង គណនេយ្យករសាធារណៈនៅតាមខេត្តក្រុង នឹងត្រូវមានការកំណត់សំរេចជាក្រោយ ។

**ប្រការ ២ :** ចំពោះចំណូលពន្ធអាករ និងចំណូលផ្សេងៗ មានលក្ខណៈប្រហាក់ប្រហែលផលិតទ្រព្យរដ្ឋពិន័យ និងទណ្ឌវាទ ពិន័យជាប្រាក់កាស ត្រូវបានជំរះបញ្ជីផ្ទៀងផ្ទាត់មុននឹងធ្វើការប្រមូល ហើយត្រូវប្រមូលដោយដីកាចំណូល ។ ចំណូលថវិកាផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទបញ្ញាជាធរមាន ឬដោយការសំរេចរបស់តុលាការ ឬដោយអនុសញ្ញាផ្សេងៗទៀត ត្រូវជំរះបញ្ជី និងធ្វើការ ប្រមូលក្នុងល័ក្ខខ័ណ្ឌបញ្ញត្តិដោយលាយ ល័ក្ខអក្សរ ចំពោះចំណូលនិមួយៗនោះ ។

**ប្រការ ៣ :** ពិន័យរបស់នគរបាលពីបទល្មើសចរាចរ ត្រូវបានប្រមូលដោយស្នងការនគរបាល ដែលត្រូវ បង្កើតជារដ្ឋទេយ្យចំណូលដោយប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ភ្នាក់ងារនគរបាលត្រូវធ្វើកំណត់ហេតុផ្តល់ទៅអ្នកប្រព្រឹត្ត បទល្មើស ព្រមទាំងអញ្ជើញគេអោយ ទៅស្នងការនគរបាល ដើម្បីបង់ប្រាក់ពិន័យ ។

**ប្រការ ៤ :** គណនេយ្យកររដ្ឋបាល ហិរញ្ញវត្ថុ នាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ និងរដ្ឋទេយ្យករចំណូល ត្រូវបង់ចំណូលដែលខ្លួនបានទទួលទៅ អោយគណនេយ្យ ករមុខការ យ៉ាងតិចណាស់ក្នុងមួយខែម្តង រៀងរាល់ថ្ងៃទី ២៥ នៃខែនីមួយៗ និងថ្ងៃទី ៣១ ខែធ្នូ និងរាល់ពេលវេលាដែលគណនេយ្យករ មានប្រាក់ ក្នុងបេឡាលើសកំរិត នៃចំនួនប្រាក់ដែល បាន កំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៥ :** មុននឹងគណនេយ្យករធ្វើការបើកផ្តល់ ចំណាយរបស់រដ្ឋ ត្រូវបានធ្វើកិច្ចសន្យាជំរះ បញ្ជី និង ធ្វើអាណាប័ណ្ណដោយអាណាប័ក ។ នីតិវិធីនៃកិច្ចសន្យា ជំរះបញ្ជី និង អាណាប័ណ្ណ នឹងត្រូវ បញ្ជាក់ដោយសារាចរណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៦ :** ដើម្បីត្រួតពិនិត្យដំបូងរាល់ការចំណាយ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើង ហើយការបង្កើតនេះ ត្រូវអនុវត្តទៅតាមនិតិវិធី ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។ កិច្ចប្រតិបត្តិការនេះ ត្រូវធ្វើឡើងតាមរយៈ ប្រកាស និងការណែនាំដោយឡែក ។

**ប្រការ ៧ :** ការចំណាយណា ដែលមានទឹកប្រាក់ច្រើនជាងការកំណត់ ត្រូវអនុវត្តទៅតាម បែបបទ ដែលបានចែងក្នុង ប្រកាសលេខ ៣១៩៩ សហវ.ម ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការចំណាយធ្វើឡើងដោយ អាបណាសញ្ញាទាំងឡាយ ក្រោមរូបភាពដេញថ្លៃ ហើយត្រូវ សហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានលទ្ធកម្ម សាធារណៈ ដែលការរៀបចំ និងដំណើរការ ត្រូវបានកំណត់ ដោយអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ។

**ប្រការ ៨ :** រាល់ការចំណាយរបស់រដ្ឋ ត្រូវធ្វើការបើកផ្តល់ដោយផ្ទាល់ពីរតនាគារជាតិ ឬរតនាគារ ខេត្ត ក្រុងក្រោយពីសេវាកម្មបានធ្វើហើយ ។ រាល់ការបើកផ្តល់ ដែលមានចំនួនទឹក

ប្រាក់លើសពី ២.៥០០.០០០ រៀលឡើងទៅ អាចធ្វើការទូទាត់តាមរយៈធនាគារ ឬមូលប្បទានប័ត្រ ។

**ប្រការ ៩ :** ការលើកលែងនូវគោលការណ៍ ដែលបានរៀបរាប់ក្នុងប្រការមុន អាចអនុវត្តបាន ចំពោះប្រភេទចំណាយមួយចំនួន និងចំណាយសំភារៈ ព្រមទាំងការថែទាំដែលមានទឹកប្រាក់ទាបជាង ៥០០.០០០ រៀល ហើយអាចប្រព្រឹត្តទៅតាមរជ្ជទេយ្យបុរេប្រទាន ។ ដោយឡែកការ ចំណាយ តាមរបៀប [illegible] និង ពលិពិការត្រូវធ្វើឡើងតាមរយៈភ្នាក់ងារ បើកផ្តល់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរជ្ជទេយ្យ ព្រមទាំងភ្នាក់ងារបើកផ្តល់ ត្រូវបានកំណត់រួមដោយរដ្ឋមន្ត្រីក្រសួងសាមី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវមានសារាចរណែនាំអោយអនុវត្តផង ។

**ប្រការ ១០ :** គណនេយ្យរបស់រដ្ឋ ត្រូវប្រកាន់យកនូវគណនេយ្យទ្វេភាគ និងជារូបិយវត្ថុជាតិ តាមប្លង់គណនេយ្យទូទៅនៃកម្ពុជាជាធរមាន ។ អាណាប័កអាចកាន់គណនេយ្យរដ្ឋបាលសាមញ្ញ ។ រូបិយប័ណ្ណបរទេស ដែលបានទទួលជាចំណូលត្រូវបង់ទៅធនាគារជាតិជាបន្ទាន់ហើយ ធនាគារជាតិនៃកម្ពុជា នឹងប្តូរជារូបិយវត្ថុជាតិ មុននឹងបង្វែរទឹកប្រាក់នេះចូលទៅក្នុងគណនី រតនាគារជាតិ ឬរតនាគារខេត្ត ក្រុង ។ ចំពោះការចំណាយជារូបិយប័ណ្ណវិញ ធនាគារជាតិ នៃ កម្ពុជាត្រូវធានានូវកិច្ចប្រតិបត្តិប្តូរនេះ ។

**ប្រការ ១១ :** សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២:** ក្នុងពេលអនុវត្តប្រកាសនេះ បើប្រសិនណាជាមានជួបការលំបាក ដោយប្រការណាមួយនោះ សូមអញ្ជើញមកទាក់ទងផ្ទាល់ ឬតាមលិខិតស្នាមផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ១៣:** មន្ទីរ នាយកដ្ឋានពន្ធដារ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុ រតនាគារជាតិ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦ នេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា និង ត្រា**
**គាត ឈន់**

* * *

# ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

**ប្រកាសលេខ :០៧ ឧក.ប្រក**

* * *

**ប្រការ១ :** អនុញ្ញាតអោយលោក **ម៉ិត ចាន់ឆូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២៧៥៤៦ ភ.ព ចុះថ្ងៃទី ០៩ - ០១ - ៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨៥ អឺ០ ផ្លូវម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរ ការសហគ្រាសកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ២ :** ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *